ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 08-Apr-2011, 14:33
CMS/CFO: Uch Arun

**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អជសដ

ភាគីដាក់ឯកសារ: សហមេធាវីរបស់លោក អៀង សារី

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ៨ ខែ មេសា ឆ្នាំ ២០១១

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ **សាធារណៈ/Public**

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

## បញ្ជីឯកសារបឋមទី២ របស់លោក អៀង សារី

---

| ដាក់ដោយ៖ | ផ្ញើជូន៖ | ផ្ញើជូន៖ |
|---|---|---|
| **សហមេធាវីរបស់លោក អៀង សារី** | **អង្គជំនុំជម្រះសាលាដំបូង** | **សហព្រះរាជអាជ្ញា** |
| លោក អាង ឧត្តម | ចៅក្រម និល ណុន | លោកស្រី ជា លាង |
| លោក Michael G. KARNAVAS | ចៅក្រម ធូ មណី | លោក Andrew CAYLEY |
| | ចៅក្រម យ៉ា សុខន | |
| | ចៅក្រម Silvia CARTWRIGHT | **ក្រុមមេធាវីការពារក្តីទាំងអស់** |
| | ចៅក្រម Jean-Marc LAVERGNE | |
| | ចៅក្រមបំរុង យូរ ឧត្តរ៉ា | |
| | ចៅក្រមបំរុង Claudia FENZ | |

លោក **អៀង សារី** តាមរយៈសហមេធាវីរបស់គាត់ (“មេធាវីការពារក្តី”) តទៅនេះសូមដាក់បញ្ជីឯកសារបឋមលើកទី២ អនុលោមតាមដីការបស់អង្គជំនុំជម្រះសាលាដំបូងបង្គាប់ឲ្យភាគីដាក់ឯកសារដើម្បីរៀបចំសវនាការ(“ដីកាបង្គាប់”)[1]។ ឧបសម្ព័ន្ធ ក មានបញ្ជីឯកសារដែលបានមកពីឃ្លាំងផ្ទុកឯកសាររួម (“SMD”) និងមានការពិពណ៌នាដោយសង្ខេបអំពីខ្លឹមសារ និងលក្ខណៈរបស់ឯកសារទាំងនោះក្នុងករណីដែលអាចធ្វើទៅបាន។ ញត្តិនេះត្រូវបានធ្វើឡើងដើម្បីគោរពទៅតាមដីការបស់អង្គជំនុំជម្រះសាលាដំបូងក្នុងកម្រិតមួយដែលអាចធ្វើទៅបាន។

## I សាវតារ

១. កាលពីថ្ងៃទី១៧ ខែមករា ឆ្នាំ២០១១ អង្គជំនុំជម្រះសាលាដំបូងបានបង្គាប់ឲ្យភាគីផ្តល់សម្ភារៈខាងក្រោមនេះឲ្យបានមុនថ្ងៃទី១៣ ខែមេសា ឆ្នាំ២០១១៖

i) បញ្ជីឯកសារដែលមាននៅក្នុងសំណុំរឿងរួចហើយ ដែលភាគីមានបំណងដាក់នៅចំពោះមុខអង្គជំនុំជម្រះ ដោយត្រូវបង្ហាញនូវអត្តសញ្ញាណឲ្យបានសមស្របតាមរយៈលេខយោងឯកសារ ចំណងជើង ភាសាដែលមាន ហើយត្រូវពន្យល់ដោយសង្ខេបអំពីលក្ខណៈ និងខ្លឹមសាររបស់វា ។

ii) បញ្ជីឯកសារថ្មី ដែលភាគីមានបំណងដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ដោយមានការពន្យល់ដោយសង្ខេបអំពីលក្ខណៈ និងខ្លឹមសាររបស់វា និង

iii) “តារាងឯកសារភស្តុតាង” ដែលចង្អុលបង្ហាញនូវភស្តុតាងជាឯកសារ ដែលភាគីនឹងយកប្រើទាក់ទងនឹងការចោទប្រកាន់ ដែលមាននៅក្នុងដីកាដំណោះស្រាយចំពោះអង្គហេតុដែលត្រូវបញ្ជាក់ដោយភស្តុតាងនីមួយៗ[2] ។

២. នៅពីថ្ងៃទី១ ខែមេសា ឆ្នាំ២០១១ មេធាវីការពារក្តី បានដាក់ញត្តិជាមួយនឹងបញ្ជីឯកសារបឋមរបស់ខ្លួន (“បញ្ជីឯកសារបឋមលើកទី១ របស់លោក អៀង សារី”)[3]។ អនុលោមតាមដីកាបង្គាប់

---

[1] *ករណី នួន ជា* ០០២-១៩-០៩-២០០៧-អវតក/អជសដ ដីកាបង្គាប់ឲ្យដាក់សម្ភារៈដើម្បីរៀបចំសវនាការ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១១ E9, ERN: 00635754-00635759 ។

[2] ដូចជើងទំព័រខាងលើ,កថាខណ្ឌទី ១២ ។

[3] *ករណី អៀង សារី* ០០២-១៩-០៩-២០០៧-អវតក/អជសដ, បញ្ជីឯកសារបឋមដែលមានក្នុងសំណុំរឿងរបស់លោក អៀង សារី និងការជូនដំណឹងទាក់ទងនឹងបញ្ជីឯកសារបឋមថ្មីសម្រាប់ដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនៅសវនាការ, ថ្ងៃទី១ ខែមេសា ឆ្នាំ២០១១, E22/9, ERN: 00659454-00659459។

របស់អង្គជំនុំជម្រះសាលាដំបូងឯកសារដែលដាក់តាមញត្តិនេះ គឺជាឯកសារដែលមាននៅក្នុងសំណុំរឿងរួចហើយ ។ ម្យ៉ាងវិញទៀត មេធាវីការពារក្តីបានលើកឡើងនៅក្នុងញត្តិនេះ៖ “មេធាវីការពារក្តីកំពុងតែពិនិត្យឯកសារចំនួន ១៩,៣៧០ ឯកសារនៅក្នុងឃ្លាំងផ្ទុកឯកសាររួម ប៉ុន្តែថា មេធាវីការពារក្តី មិនអាចបញ្ចប់ភារកិច្ចនេះតាមការកំណត់របស់អង្គជំនុំជម្រះសាលាដំបូងបានឡើយ ព្រោះមេធាវីការពារក្តីក៏ត្រូវការពិនិត្យមើលឯកសារជាង ៧០,០០០ ឯកសារនៅក្នុងសំណុំរឿងផងដែរ”[4] ។

៣. កិច្ចប្រជុំរៀបចំសវនាការត្រូវបានធ្វើឡើងកាលពីថ្ងៃ៥ ខែមេសា ឆ្នាំ២០១១[5]។ ក្នុងអំឡុងកិច្ចប្រជុំនោះ អង្គជំនុំជម្រះសាលាដំបូងបានលើកឡើងថា សវនាការនឹងត្រូវចែកជាច្រើនវគ្គដើម្បីពិភាក្សាលើប្រធានបទផ្សេងៗគ្នា ។ បួនវគ្គដំបូងគឺមានដូចខាងក្រោម:

ក) រចនាសម្ព័ន្ធកម្ពុជាប្រជាធិបតេយ្យ ។

ខ) តួនាទីរបស់ជនជាប់ចោទ ក្នុងរយៈកាលនៅមុនការបង្កើតរបបកម្ពុជាប្រជាធិបតេយ្យ រួមបញ្ចូលថាតើតួនាទីទាំងនេះត្រូវបានចាត់តាំងនៅពេលណាផងដែរ ។

គ) តួនាទីរបស់ជនជាប់ចោទនីមួយៗ នៅក្នុងរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ការទទួលខុសត្រូវរបស់ជនជាប់ចោទដែលត្រូវបានចាត់តាំង វិសាលភាពនៃអំណាចរបស់ជនចាប់ចោទ និងប្រព័ន្ធទំនាក់ទំនងនៅទូទាំងយុត្តាធិការពេលវេលារបស់ អវតក។

ឃ) គោលនយោបាយរបស់កម្ពុជាប្រជាធិបតេយ្យ ទៅលើបញ្ហាដែលបានលើកឡើងក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ[6]។

៤. នៅក្នុងកិច្ចប្រជុំរៀបចំសវនាការ អង្គជំនុំជម្រះសាលាដំបូងបានលើកឡើងថា ភាគីត្រូវតែផ្តល់បញ្ជីឯកសារជាមុន ដែលភាគីមានបំណងលើកមកសំអាងនៅក្នុងវគ្គនីមួយៗនៃសវនាការ នៅមុនពេល

---

[4] ដូចជើងទំព័រខាងលើ, កថាខណ្ឌទី៣៤។

[5] *ករណី នួន ជា* ០០២-១៩-០៩-២០០៧-អវតក/អជសដ, របៀបវារៈសម្រាប់កិច្ចប្រជុំរៀបចំសវនាការ, ចុះថ្ងៃទី១៧ ខែមិនា ឆ្នាំ ២០១១, ឯកសារ E9/5/1, ERN: 00652421-00652423 ។

[6] *ករណី នួន ជា* ០០២-១៩-០៩-២០០៧-អវតក/អជសដ, ប្រតិចារិកនៃសវនាការ, កិច្ចប្រជុំរៀបចំសវនាការ, ថ្ងៃទី៥ ខែមេសា ឆ្នាំ ២០០១, ទំព័រទី៥២។

វគ្គសវនាការចាប់ផ្តើម (“បញ្ជីឯកសារដែលត្រូវផ្តល់ឲ្យជាមុន”)[7]។ បន្ទាប់មកសហព្រះរាជអាជ្ញារងអន្តរជាតិបានចោទសួរថា “តើបញ្ជីឯកសារដែលភាគី និងព្រះរាជអាជ្ញានឹងត្រូវដាក់យ៉ាងដូម្តេច នាថ្ងៃទី ១៣ មេសា ២០១១ ហើយវាទាក់ទងគ្នាយ៉ាងម៉េចទៅនឹង បញ្ជីឯកសារដែលត្រូវផ្តល់ឲ្យជាមុននៃភស្តុតាង ដែលលោកចៅក្រមនិយាយសំដៅទៅនោះ?[8] ។ ចៅក្រម Cartwright បានឆ្លើយតបថា “គោលបំណងនោះគឺថា នៅមុនការចាប់ផ្តើមនៃវគ្គនីមួយៗនៃសវនាការ ... ភាគីត្រូវបញ្ជាក់នូវឯកសារណាមួយរបស់ខ្លួនដែលបានជូនដំណឹងមករួចហើយនៅក្នុងបញ្ជីឯកសារទាំងមូលរបស់ខ្លួន គឺជាឯកសារដែលមានជាប់ពាក់ព័ន្ធទៅនឹងផ្នែកនៃសវនាការនោះ[9] ។

## II. អំណះអំណាង

៥. បន្ទាប់ពីមានការបញ្ជាក់របស់ចៅក្រម Cartwright និងការជូនដំណឹងរបស់មេធាវីការពារក្តីដល់អង្គជំនុំជម្រះសាលាដំបូង និងភាគីទាំងអស់ក្នុងសំណុំរឿង០០២ថាខ្លួនកំពុងតែពិនិត្យមើលឯកសារចំនួន១៩,៣៧០ ឯកសារនៅក្នុងឃ្លាំងផ្ទុកឯកសាររួម ប៉ុន្តែមិនអាចធ្វើកិច្ចនេះតាមការកំណត់របស់អង្គជំនុំជម្រះសាលាដំបូងបាននោះ[10] មេធាវីការពារក្តីបានដាក់ឯកសារទាំងអស់ដែលមាននៅក្នុងឃ្លាំងផ្ទុកឯកសាររួមទៅក្នុងបញ្ជីឯកសារពេញលេញរបស់ខ្លួន ដូចដែលបានតម្រូវដោយដីកាបង្គាប់របស់អង្គជំនុំជម្រះសាលាដំបូង[11]។ បញ្ជីឯកសារនេះនឹងត្រូវដាក់នៅដំណាក់កាលដំបូងបំផុតតាមដែលអាចធ្វើទៅបាន បន្ទាប់ពីមានការបញ្ជាក់នេះ ដើម្បីផ្តល់ឲ្យអង្គជំនុំជម្រះសាលាដំបូង និងភាគីនូវពេលវេលាច្រើនបំផុតនៅមុនសវនាការ ដើម្បីពិនិត្យមើលបញ្ជីឯកសារពេញលេញរបស់មេធាវីការពារក្តី ។ ដូចដែលបានលើកឡើងនៅក្នុងបញ្ជីឯកសារបឋមរបស់លោក អៀង សារី មេធាវីការពារក្តីមិនអាចបង្ហាញព័ត៌មាននេះតាមរយៈ “តារាងឯកសារភស្តុតាង” បានឡើយដោយសារតែឯកសារនៅក្នុងឃ្លាំងផ្ទុកឯកសាររួមមានចំនួនរហូតដល់ ១៩,៣៧០ ឯកសារឯណោះ និងប្រការដែលថាឯកសារនៅក្នុងឃ្លាំងផ្ទុកឯកសាររួម មិនត្រូវបានគេរៀបតាមប្រធានបទភស្តុតាងដែលពាក់ព័ន្ធនឹងឯកសារនោះនៅឡើយទេ[12] ។ មេធាវីការពារក្តីនឹងព្យាយាមផ្តល់ឯកសារក្នុងបញ្ជី

---

[7] *ដូចជើងទំព័រខាងលើ* ទំព័រ ៧១។

[8] ដូចជើងទំព័រខាងលើ, ទំព័រ ៧២។

[9] ដូចជើងទំព័រខាងលើ, ទំព័រ ៧៣។

[10] បញ្ជីឯកសារបឋមរបស់ អៀង សារី, កថាខណ្ឌទី៣៤។

[11] សូមមើលឧបសម្ព័ន្ធ ក។

[12] បញ្ជីឯកសារបឋមរបស់ អៀង សារី, កថាខណ្ឌទី២៧។

ឯកសារដែលផ្តល់ឲ្យជាមុននីមួយៗ តាមរយៈតារាងឯកសារភស្តុតាង ប្រសិនបើមានការស្នើសុំពីអង្គជំនុំជម្រះសាលាដំបូង ។

៦. មេធាវីការពារក្តី នឹងដាក់បញ្ជីឯកសារបឋមទី៣នៅមុនកាលកំណត់នៅក្នុងដីកាបង្គាប់ឲ្យភាគីដាក់ឯកសារ និងអនុស្សរណៈបន្ទាប់ពីដីកានេះ[13]។ បញ្ជីនេះនឹងមានឯកសារដែលមិនមាននៅក្នុងសំណុំរឿង និងនៅក្នុងឃ្លាំងផ្ទុកឯកសាររួម។ ដូចដែលបានលើកឡើងក្នុង បញ្ជីឯកសារបឋមលើកទី១របស់លោក អៀង សារី មេធាវីការពារក្តីសូមរក្សាសិទ្ធិបំពេញបន្ថែមបញ្ជីនេះក្នុងដំណាក់កាលក្រោយមកទៀត[14]។ ម្យ៉ាងវិញទៀត

> នៅពេលនេះ មេធាវីការពារក្តីមិនអាចដាក់បញ្ជីសម្ភារៈពេញលេញដែលខ្លួនមានបំណងដាក់នៅចំពោះមុខអង្គបុរេជំនុំជម្រះបានឡើយ។ បញ្ហានេះ បណ្តាលមកពី៖...២) មេធាវីការពារក្តីមិនទាន់អាចកំណត់ថាតើឯកសារណាខ្លះមានក្នុងសំណុំរឿងរួចហើយ ៣) មេធាវីការពារក្តីមិនអាចពិនិត្យមើលឯកសារទាំងអស់ក្នុងឃ្លាំងផ្ទុកឯកសាររួមបានឡើយ និង ៤) មេធាវីការពារក្តីត្រូវបានហាមឃាត់មិនឲ្យធ្វើការស៊ើបអង្កេតនៅពេលដែល កសចស បានទទួលសំណុំរឿង[15]។

៧. ក្នុងអំឡុងពេលនៃកិច្ចប្រជុំរៀបចំសវនាការ អង្គជំនុំជម្រះសាលាដំបូងបានលើកឡើងជាច្រើនដងថាអង្គជំនុំជម្រះសាដំបូងអាចបត់បែនក្នុងការធ្វើចំណាត់ការរបស់ខ្លួនចំពោះដំណើការសវនាការសំណុំរឿង ០០២[16] ។ ការផ្តល់ឲ្យមេធាវីការពារក្តីនូវសិទ្ធិបំពេញបន្ថែមបញ្ជីឯកសារដែលមិនទាន់មាននៅក្នុងសំណុំរឿង ឬ ឃ្លាំងផ្ទុកឯកសាររួម នឹងស៊ីសង្វាក់គ្នា ហើយនឹងស្របតាមបំណងរបស់អង្គជំនុំជម្រះសាលាដំបូង ដើម្បីចាប់ផ្តើមសវនាការក្នុងសំណុំរឿង០០២តាមរបៀបមួយដែលមានលក្ខណៈបត់បែន ។ ការរៀបចំឯកសារដែលមិនទាន់មាននៅក្នុងសំណុំរឿង ឬនៅក្នុងឃ្លាំងផ្ទុកឯកសាររួម គឺជាភារកិច្ចដ៏មហាសែនលំបាក (Herculean) បើពីចារណាពីចំនួនឯកសារដែលមាន និងចំនួនបញ្ហាដែលនឹងត្រូវដោះស្រាយក្នុងពេលសវនាការ ។ បញ្ហាជាច្រើនថែមទៀត ទំនងជានឹងកើតឡើងបន្ទាប់ពីការបង្ហាញភស្តុតាងដោយតម្រូវឲ្យមានឯកសារបន្ថែមទៀត ដែលមិនទាន់

---

[13] *ករណី នួន ជា* ០០២-១៩-០៩-២០០៧-អវតក/អជសង, ការឈប់សម្រាករបស់តុលាការក្នុងឱកាសបុណ្យចូលឆ្នាំខ្មែរ, ថ្ងៃទី ២៨ ខែមីនា ឆ្នាំ២០១១, ឯកសារ E68, ERN: 00656878-00656878។

[14] បញ្ជីឯកសារបឋមរបស់ អៀង សារី, កថាខណ្ឌទី៣០។

[15] ដូចជើងទំព័រខាងលើ។

[16] *ករណី នួន ជា* ០០២-១៩-០៩-២០០៧-អវតក/អជសង, ប្រតិចារិកនៃសវនាការ, កិច្ចប្រជុំរៀបចំសវនាការ ថ្ងៃទី៥ ខែមេសា ឆ្នាំ ២០០១, ទំព័រ ៧ ដល់ ១៥។

មាននៅក្នុងបញ្ជីឯកសារពេញលេញរបស់មេធាវីការពារក្តី ។ អង្គជំនុំជម្រះសាលាដំបូងត្រូវតែប្រើ ដំណោះស្រាយដែលមានលក្ខណៈបត់បែនដើម្បីនាំទៅដល់ការស្វែងរកការពិត ។

សូមចៅក្រមអង្គជំនុំជម្រះសាលាដំបូងទទួលយកញ្ញត្តិនេះដោយក្តីគោរព។

ធ្វើនៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី **៨** **ខែមេសា** ឆ្នាំ **២០១១**

**អាង ឧត្តម** Michael G. KARNAVAS

សហមេធាវីរបស់លោក **អៀង សារី**